00644223

E47

# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជសង

ភាគីដាក់ឯកសារ: លោក ខៀវ សំផន

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: **បារាំង**

កាលបរិច្ឆេទឯកសារ: ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយសាលាដំបូង សាធារណៈ / Public

ប្រភេទនៃចំណាត់

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## អញ្ញត្រកម្មបឋម ស្ដីពីការរលត់បណ្ដឹងអាជ្ញា (បទល្មើសជាតិ)

---

**ដាក់ដោយ៖**

**សហមេធាវីការពារក្ដីលោក ខៀវ សំផន**

លោក ស សូវ៉ាន

លោក Jacques VERGES

លោក Philippe GRECIANO

**ផ្ញើជូន៖**

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន

ចៅក្រម Mme Silvia CARTWRIGHT

ចៅក្រម ធូ មណី

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ា សុខន

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Andrew CAYLEY

**មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**ឯកសារទទួល**
DOCUMENT RECEIVED/DOCUMENT REÇU

ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 14 / 02 / 2011

ម៉ោង (Time/Heure): 15:40

មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

E47

លោក ពេជ្រ អង្គ

លោកស្រី Elisabeth SIMONNEAU FORT

# សូមគោរពអង្គជំនុំជម្រះសាលាដំបូង

## I. ការរំឭកពីនីតិវិធី

១. កាលពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ អង្គបុរេជំនុំជម្រះបានបញ្ជូន លោក ខៀវ សំផន ទៅកាន់អង្គជំនុំជម្រះសាលាដំបូង[1] ដើម្បីវិនិច្ឆ័យលើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អំពើប្រល័យពូជសាសន៍ និងការបំពារបំពានធ្ងន់ធ្ងរទៅលើសន្ធិសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ និងបទល្មើសដូចមានចែងក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦[2]។

## II. សេចក្តីផ្តើម

២. ថ្ងៃនេះ លោក ខៀវ សំផន សូមដាក់អញ្ញត្រកម្មបឋមស្តីពីការរលត់បណ្តឹងអាជ្ញា ដោយផ្អែកទៅលើវិធាន ៨៩(១)(ខ) នៃវិធានផ្ទៃក្នុង របស់ អ.វ.ត.ក ("វិធានផ្ទៃក្នុង")។ នៅថ្ងៃដដែលនេះ លោក ខៀវ សំផន ក៏បានដាក់អញ្ញត្រកម្មបឋមពាក់ព័ន្ធទៅនឹងយុត្តាធិការតុលាការដោយយោងតាមវិធាន ៨៩(១)(ខ) នៃវិធានផ្ទៃក្នុងផងដែរ។ ដោយសារតែមានការកម្រិតចំនួនទំព័រ បណ្តឹងទាំងនោះត្រូវបានធ្វើឡើងជាលក្ខណៈសង្ខេបខ្លីៗ។ លោកសុំរក្សាសិទ្ធិពង្រីកនូវចំណុចទាំងនោះ ក្នុងសេចក្តីសន្និដ្ឋានបន្ថែម។

### ក. គោលការណ៍ទូទៅនៃច្បាប់

៣. លោក ខៀវ សំផន សូមលើកឡើងដដែលៗពីសារសំខាន់នៃគោលការណ៍ សមភាពនៅចំពោះមុខច្បាប់ នីត្យានុកូលភាព និងអប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ។ គោលការណ៍ទី១មានចែងនៅក្នុងមាត្រា ៣០ និង៨១ នៃរដ្ឋធម្មនុញ្ញកម្ពុជាបច្ចុប្បន្ននេះ ព្រមទាំងមាត្រា ៣ នៃក្រមនីតិព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៨ មាត្រា ៧ នៃសេចក្តីប្រកាសជាសាកលនៃសិទ្ធិមនុស្ស និងមាត្រា១៤(១) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ គោលការណ៍ទាំងនេះចង់ឲ្យរាល់ពលរដ្ឋគ្រប់រូប ដែលរស់នៅក្នុងប្រទេសតែមួយ មានសិទ្ធិស្មើៗគ្នានៅចំពោះមុខច្បាប់។ ឯគោលការណ៍ចុងក្រោយពីរទៀត តម្រូវឲ្យអង្គជំនុំជម្រះអនុវត្តច្បាប់ព្រហ្មទណ្ឌ

---

[1] ដីកាសម្រេចពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍របស់លោក ខៀវ សំផនប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារតុលាការ D427/4/14

[2] ដីកាដំណោះស្រាយ ថ្ងៃទី១៦ ខែកញ្ញា ឯកសារតុលាការ ឆ្នាំ២០១០ D427, កថាខណ្ឌ១៦១៣។

ដែលចូលជាធរមាន នៅក្នុងខណៈដែលបទល្មើសនោះត្រូវបានសន្មតថាបានប្រព្រឹត្តឡើង។[3]

## ខ. ច្បាប់អនុវត្តន៍

៤. មាត្រា ១០៩ នៃក្រមនីតិព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ពាក់ព័ន្ធទៅនឹងអាជ្ញាយុកាលនៃបទឧក្រិដ្ឋ ចែងថា "អ្នកណាប្រព្រឹត្តឧក្រិដ្ឋកម្មកន្លងលើសពីដប់ឆ្នាំ អ្នកនោះបានរួចផុតពីមានទោសហើយ"។ មាត្រា១១ នៃក្រមដដែលនេះចែងផងដែរថា អាជ្ញាយុកាលនេះត្រូវចាប់កំណត់ពីត្រឹមថ្ងៃដែលបទល្មើសនោះបានកើតឡើងរួចមក។ មានតែចំណាត់ការរបស់នគរបាលយុត្តិធម៌ ឬព្រះរាជអាជ្ញាទេដែលអាចបញ្ឈប់ចិរវេលាអាជ្ញាយុកាលបាន[4]។

៥. នៅថ្ងៃទី២ ខែមករា ឆ្នាំ២០០១ រដ្ឋសភាបានបោះឆ្នោតលើគម្រោងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ("ច្បាប់ឆ្នាំ២០០១ស្តីពីអ.វ.ត.ក")[5]។ ច្បាប់ឆ្នាំ២០០១ស្តីពីអ.វ.ត.ក ផ្តល់សមត្ថកិច្ចដល់អង្គជំនុំជម្រះ ដើម្បីវិនិច្ឆ័យទោសចំពោះអំពើឃាតកម្ម ទារុណកម្ម និងការធ្វើទុក្ខបុកម្នេញខាងសាសនា ស្របតាមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។ ច្បាប់នេះក៏បានពន្យារអាជ្ញាយុកាលនៃទោសឧក្រិដ្ឋទាំងនេះដល់រយៈពេល២០ឆ្នាំផងដែរ[6]។

៦. ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០១ ក្រុមប្រឹក្សាធម្មនុញ្ញ បានប្រកាសច្បាប់ឆ្នាំ២០០១ស្តីពីអ.វ.ត.ក ថា ស្របនឹងរដ្ឋធម្មនុញ្ញ លុះណាតែលុបចោលបទបញ្ញត្តិពាក់ព័ន្ធនឹងទោសប្រហារជីវិត[7]។

---

[3] គោលការណ៍ទាំងនេះមានចែងក្នុង៖ មាត្រា ៨ នៃសេចក្តីប្រកាសស្តីពីសិទ្ធិមនុស្ស និងពលរដ្ឋ ឆ្នាំ ១៧៨៩ មាត្រា ១១ នៃសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស មាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ មាត្រា ៣៣ (២) នៃច្បាប់ស្តីពីអវតក មាត្រា ៦ នៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦។

[4] សូមមើលមាត្រា៣៧នៃក្រមនីតិព្រហ្មទណ្ឌកម្ពុជា នាឆ្នាំ១៩៦៤ នៃព្រះរាជាណាចក្រកម្ពុជា៖ "បណ្តឹងអាជ្ញាក្នុងការអនុវត្តទោស អាចរលត់ទៅបានតែ (...) តាមចិរវេលាអាជ្ញាយុកាលដូចមានចែងក្នុងមាត្រា១០៩ និង១១ នៃក្រមព្រហ្មទណ្ឌ [...]"។ សូមមើលផងដែរនូវមាត្រា៣៨ និង២១ នៃក្រមដដែលនេះ (ដែលកំណត់ការបញ្ឈប់ ឬព្យួរបណ្តឹងអាជ្ញា ដោយរង់ចាំសេចក្តីសម្រេចជាមុនរបស់តុលាការស៊ីវិល ទៅលើបញ្ហាបន្ទាន់បង្គំសិន។

[5] សូមមើលបុព្វបទនៃច្បាប់ឆ្នាំ២០០៤ ពាក់ព័ន្ធនឹងការបង្កើត បង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីជំនុំជម្រះលើបទឧក្រិដ្ឋប្រព្រឹត្តឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ("ច្បាប់ឆ្នាំ២០០៤ស្តីពីអ.វ.ត.ក")។

[6] មាត្រា៣ នៃច្បាប់ឆ្នាំ២០០៤ ស្តីពីអ.វ.ត.ក។

[7] សូមមើលបុព្វបទ នៃច្បាប់ឆ្នាំ២០០៤ស្តីពីអ.វ.ត.ក។

ច្បាប់ឆ្នាំ២០០១ស្តីពីអ.វ.ត.ក បានចូលជាធរមាន នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ បន្ទាប់ពីត្រូវបានប្រកាសអោយប្រើដោយព្រះមហាក្សត្រ នរោត្តម សីហនុ។

៧. ដើម្បីឱ្យស្របតាមកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ពាក់ព័ន្ធនឹងការចោទប្រកាន់លើជនទាំងឡាយដែលបានប្រព្រឹត្តអំពើឧក្រិដ្ឋក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ដោយអនុវត្តតាមច្បាប់កម្ពុជា("កិច្ចព្រមព្រៀង")[8] ច្បាប់ឆ្នាំ២០០១ស្តីពីអ.វ.ត.ក ត្រូវបានធ្វើការកែប្រែ និងប្រកាសឱ្យប្រើ នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ (បន្ទាប់ពីត្រូវបានវិនិច្ឆ័យដោយក្រុមប្រឹក្សាធម្មនុញ្ញថា ស្របតាមរដ្ឋធម្មនុញ្ញ នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៤)។ មាត្រា៣ (ថ្មី) នៃច្បាប់ឆ្នាំ២០០៤ស្តីពីអ.វ.ត.ក បានពន្យារពេលបន្ថែម "៣០ឆ្នាំទៀតទៅលើអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាសម្រាប់ឧក្រិដ្ឋកម្មទាំងឡាយខាងលើដែលស្ថិតក្នុងសមត្ថកិច្ចនៃអង្គជំនុំជម្រះវិសាមញ្ញ ដូចមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦។[9]"

## គ. អំណះអំណាង

៨. មាត្រា៣ (ថ្មី) នៃច្បាប់ឆ្នាំ២០០៤ស្តីពីអ.វ.ត.ក រំលោភទៅលើគោលការណ៍សមភាពចំពោះមុខច្បាប់ គោលការណ៍អប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ។

### ក. គោលការណ៏សមភាពចំពោះមុខច្បាប់

៩. មាត្រា៣ (ថ្មី) នៃច្បាប់ឆ្នាំ២០០៤ស្តីពីអ.វ.ត.ក ត្រូវបានយកមកអនុវត្ត ដោយគិតតែត្រឹមបទឧក្រិដ្ឋដែលស្ថិតក្នុងយុត្តាធិការនៃ អ.វ.ត.ក ប៉ុណ្ណោះ។ យុត្តាធិការនៃ អ.វ.ត.ក កម្រិតត្រឹមតែសមត្ថកិច្ចតាមពេលវេលា *(rationae temporae)* ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តទៅក្នុងអម្លុងថ្ងៃ១៧ មេសា ១៩៧៥ ដល់ថ្ងៃ៦ មករា ១៩៧៩ ប៉ុណ្ណោះ និងកម្រិតត្រឹមតែសមត្ថកិច្ចតាមបុគ្គល *(rationae personae)* ចំពោះ មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភ

---

[8] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងទៅនឹងការជំនុំជម្រះជនដែលប្រព្រឹត្តបទឧក្រិដ្ឋក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយអនុលោមទៅតាមច្បាប់កម្ពុជា។

[9] មាត្រា៣ (ថ្មី) នៃ ច្បាប់ឆ្នាំ២០០៤ស្តីពីអ.វ.ត.ក។

យ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់។ អ.វ.ត.ក មិនមានសមត្ថកិច្ចទូទៅទេ មិនត្រូវយកមាត្រា៣ (ថ្មី) នៃច្បាប់ឆ្នាំ២០០៤ ស្តីពីអ.វ.ត.ក ទៅអនុវត្តចំពោះអ្នកប្រព្រឹត្តបទឧក្រិដ្ឋដូចគ្នាទៅនឹងអ្វីដែលចោទប្រកាន់ទៅលើរូបលោក ខៀវ សំផន ឡើយ។ ដូច្នេះ មាត្រា៣ (ថ្មី) នៃច្បាប់ឆ្នាំ២០០៤ស្តីពីអ.វ.ត.ក រំលោភទៅលើគោលការណ៍សមភាពចំពោះមុខច្បាប់។

## ខ. គោលការណ៍អប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ

១០. មាត្រា ៦ នៃច្បាប់ព្រហ្មទណ្ឌឆ្នាំ១៩៥៦ ចែងពីគោលការណ៍អប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌបានតឹងរ៉ឹងជាង[10]។ មាត្រានេះអាចយកទៅអនុវត្តបាន ដរាបណាក្រមព្រហ្មទណ្ឌចូលធរមានសព្វថ្ងៃ កំណត់នូវទោសស្រាលជាងនោះ (ឧ. ការមិនអនុវត្តទោសប្រហារជីវិតចំពោះមុខ អ.វ.ត.ក)។

## គ. ការរលត់បណ្តឹងអាជ្ញាចំពោះឧក្រិដ្ឋកម្មជាតិ

១១. សហចៅក្រមស៊ើបអង្កេត “បានសម្រេចជាឯកភាពទទួលយកសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ដោយទុកលទ្ធភាពឲ្យអង្គជំនុំជម្រះសាលាដំបូង ធ្វើការវាយតម្លៃអំពីចំណាត់ការបន្តនៃនីតិវិធីដែលពាក់ព័ន្ធនឹងបទល្មើស ក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ទាំងនោះ[11]”។

### ១-ការចោទសួររបស់អង្គជំនុំជម្រះ

១២. នៅក្នុងសំណុំរឿង០០១ អង្គជំនុំជម្រះសាលាដំបូង បានបង្គាប់ឲ្យភាគីឆ្លើយទៅនឹងសំណួរដូចតទៅ៖

---

[10] “ច្បាប់ព្រហ្មទណ្ឌមិនមានអានុភាពប្រតិសកម្មទេ។ បទល្មើសណាបានប្រព្រឹត្តមុនបញ្ញត្តិច្បាប់ បទល្មើសនោះមិនអាចត្រូវនិគ្រោះដោយទោស របស់ច្បាប់ដែលបញ្ញត្តិថ្មីនោះបានទេ។ ប៉ុន្តែ បើច្បាប់ថ្មីលុបចោលបទល្មើសណាមួយ ឬសម្រាលទោសដល់បទល្មើសណាមួយវិញ បទល្មើសដែលបានប្រព្រឹត្តមុនច្បាប់ថ្មីនេះ ត្រូវបានរួចផុតពីទោស ឬក៏ទោសនោះត្រូវបានស្រាលតាមច្បាប់ថ្មីនេះដែរ កុំឲ្យតែបទល្មើសនោះបានទទួលការផ្តន្ទាជាស្ថាពររួចអស់ទៅហើយ។

[11] ដីកាដំណោះស្រាយ ឯកសារតុលាការ D427, កថាខណ្ឌ១៥៧៤។

"តើមានការបំពេញកិច្ចការតាមផ្លូវច្បាប់ណាមួយ ដូចជាការចោទប្រកាន់ ឬការស៊ើបសួរ ឬក៏កាលៈទេសៈនៃអង្គហេតុណាមួយ ដូចជាការមិនដំណើរការនូវស្ថាប័នតុលាការជាបណ្ដោះអាសន្ន ដែលអាចនាំឱ្យមានការបញ្ឈប់ឬព្យួរអាជ្ញាយុកាលដែលយកមកអនុវត្តនោះដែរទេ?

តើអាជ្ញាយុកាលដែលគ្របដណ្ដប់លើបទល្មើសខាងលើ ផុតរលត់បណ្ដឹងអាជ្ញាក្នុងការចោទប្រកាន់ជនជាប់ចោទ មុនការប្រកាសឱ្យប្រើមាត្រា៣ និង៣ថ្មី នៃ[ច្បាប់បង្កើត អ.វ.ត.ក] ទាំងពីរលើក ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ និងថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ នោះដែរឬទេ? ប្រសិនបើអាជ្ញាយុកាលផុតរលត់ តើបទបញ្ញត្តិទាំងនោះបញ្ជាក់ពីប្រតិសកម្ម ឬការអនុវត្តឡើងវិញនៃសិទ្ធិចោទប្រកាន់ដែរឬទេ ?

តើការពន្យារថិរវេលានៃអាជ្ញាយុកាលនៃបណ្ដឹង ដែលមានចែងក្នុងមាត្រា៣ និង៣ថ្មី នៃច្បាប់បង្កើត អ.វ.ត.ក ទាំងពីរលើក ជាបទបញ្ញត្តិនីតិវិធី ឬជាបទបញ្ញត្តិលើអង្គសេចក្ដី? តើគេអាចទាញសេចក្ដីសន្និដ្ឋាន ពីចរិតលក្ខណៈវិធានទាំងពីរនេះក្នុងផ្នែកគតិយុត្តិដែរឬទេ? ក្នុងករណីជាបទបញ្ញត្តិនីតិវិធី តើច្បាប់បង្កើត អ.វ.ត.ក មានចែងពីការយោងណាមួយទៅនឹងបទដ្ឋានអន្តរជាតិ ដើម្បីធ្វើការសម្រេចពីអសុពលភាពលើបទបញ្ញត្តិមួយរបស់ខ្លួនឬទេ? ប្រសិនជាមានមែន តើបទដ្ឋានអន្តរជាតិណាមួយដែលគួរយកមកអនុវត្តក្នុងករណីពិសេសនេះ ?

ក្នុងករណីយកបទដ្ឋានអន្តរជាតិមកអនុវត្ត តើអានុភាពគតិយុត្តិនៃសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០១ មកលើ អ.វ.ត.ក មានដូចម្ដេចខ្លះ [12]?"

១៣. ដោយសារតែមានស្មារតីសន្សំសំចៃក្នុងផ្លូវច្បាប់ ក្រុមមេធាវីការពារក្ដី បានសម្រេចថានឹងឆ្លើយតបយ៉ាងខ្លីទៅនឹងសំណួរទាំងនោះ នៅក្នុងបណ្ដឹងនេះ។

**ក. សេចក្ដីសង្កេតលើសំណួរទី១**

១៤. ពុំមានលិខិតធ្វើការចោទប្រកាន់ ឬការស៊ើបសួរប្រឆាំងនឹង លោក ខៀវ សំផន ដែលអាចនាំឱ្យមានការបញ្ឈប់ ឬព្យួរអាជ្ញាយុកាលដែលយកមកអនុវត្តនោះឡើយ។

១៥. លោក ខៀវ សំផន ក៏កត់សម្គាល់ផងដែរថា ធ្លាប់មានប្រព័ន្ធយុត្តិធម៌នៅកម្ពុជា ក្រោយថ្ងៃទី

---

[12] សេចក្ដីណែនាំដល់ភាគីក្នុងការដាក់សេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ពាក់ព័ន្ធនឹងអញ្ញត្រកម្មបឋមលើកឡើងដោយក្រុមមេធាវីការពារក្ដី ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៩ ឯកសារតុលាការ E9/4

៦ ខែមករា ឆ្នាំ១៩៧៩[13]។ ម៉្យាងវិញទៀត ច្បាប់ផ្សេងៗដែលមានចរិតលក្ខណៈជាអង្គការតុលាការក៏ត្រូវបានប្រកាសឲ្យប្រើប្រាស់នៅក្នុងកំឡុងពេលនោះដែរ [14]។

១៦. ការចោទប្រកាន់ត្រូវបានធ្វើឡើងប្រឆាំងនឹងជនជាប់ចោទ ដែលបានប្រព្រឹត្តបទឧក្រិដ្ឋក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយសវនាការមួយបានប្រព្រឹត្តទៅចំពោះមុខតុលាការប្រជាជនបដិវត្តន៍ ពីថ្ងៃទី១៥ ដល់ទី១៩ ខែសីហាឆ្នាំ១៩៧៩[15]។

១៧. ពេលក្រោយមកទៀត កិច្ចស៊ើបសួរថ្មីនៃអង្គការសហប្រជាជាតិ គឺជាការបើកការស៊ើបសួរបឋម ធ្វើឡើងដោយ អ.វ.ត.ក នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៦ ពីបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តដោយអ្នកដឹកនាំកម្ពុជាប្រជាធិបតេយ្យ និងមេដឹកនាំជាន់ខ្ពស់ ចន្លោះពេលរវាងថ្ងៃ១៧ មេសា ១៩៧៥ និងថ្ងៃទី៦ មករា ១៩៧៩[16]។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរធ្វើការចោទប្រកាន់លើ លោក ខៀវ សំផន នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៧[17]។

១៨. សមត្ថកិច្ចតាមពេលវេលា *(rationae temporae)* នៃអង្គជំនុំជម្រះ គិតចាប់ពីថ្ងៃទី១៧ មេសា ១៩៧៥ ដល់ថ្ងៃទី៦ មករា ១៩៧៩។ ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ចែងថាទោសនៃបទឧក្រិដ្ឋនឹងត្រូវផុតរលត់នៅក្នុងរយៈពេលដប់ឆ្នាំ។ ដូច្នេះ បើគិតតាមទ្រឹស្តីបទល្មើសដែលចោទប្រកាន់លើរូបលោក ខៀវ សំផន ត្រូវផុតរលត់តាំងពីថ្ងៃទី៦ មករា ១៩៨៩ ម្ល៉េះ។

---

[13] សូមអាន « Introduction to the Cambodian Judicial process », និពន្ធដោយ Koy Neam, The Asia Fundation, ឆ្នាំ១៩៩៨ ពីទំព័រ៥ ដល់៧ (ក្នុងសៀវភៅសរសេរជាភាសាខ្មែរ) ពីទំព័រ៣ ដល់៥ (ក្នុងសៀវភៅសរសេរជាភាសាអង់គ្លេស)។ សូមអានផងដែរ: EVAN GOTTESMAN, Cambodia after the Khmer Rouge។ ក៏សូមអានផងដែរ Basil Fernando, Problems Facing the Cambodia Legal System, The System of Trial under the Vietnamese – Khmer Model (ឆ្នាំ១៩៨១-១៩៩៣) http://www.basilfernando.net/modules.php?name=Content&pa=showpage&pid=20&cid=5

[14] ជាពិសេសសូមអាន "Law on the Organization of the Military Court", អនុក្រឹតលេខ០៥, ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៨១; "Law on the Organization of the People's Supreme Court and the General Prosecution attached to the People's Supreme Court", អនុក្រឹតលេខ២៨ករ, ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៨៥។

[15] "Decree-Law on the Establishment of People's Revolutionary Tribunal at Phnom Penh to try the Pol Pot-Ieng Sary clique for the crime of genocide", អនុក្រឹត-ច្បាប់លេខ១, ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៧៩ និង "Decree-Law on Punishment of Betrayers of the Revolution", អនុក្រឹត-ច្បាប់លេខ២, ចុះថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៨០។

[16] ដីកាដំណោះស្រាយ ថ្ងៃទី១៦ ខែកញ្ញា ឯកសារតុលាការ ឆ្នាំ២០១០ D427, កថាខណ្ឌ៣។

[17] ដូចខាងលើ

### ខ. សេចក្តីសង្កេតលើសំណួរទី២

១៩. ចៅក្រមអន្តរជាតិបានកំណត់ថា "ថិរវេលានៃអាជ្ញាយុកាលនេះបានផុតរលត់ទៅហើយ មុនពេលអនុម័តមាត្រា៣ ថ្មី អាស្រ័យហេតុនេះ ថិរវេលានៃអាជ្ញាយុកាល មិនអាច "ពន្យារ" បានទេ។ ការសន្និដ្ឋាននេះ ស្របគ្នាជាមួយការបកស្រាយទូទៅ ដែលបានគូសបញ្ជាក់នៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩ ដែលថា មិនមានតម្រូវការឲ្យបកស្រាយច្បាប់នោះទេ ប្រសិនច្បាប់នោះចែងច្បាស់លាស់ និងថាបទបញ្ញត្តិទាក់ទងនឹងបទឧក្រិដ្ឋនានា ត្រូវធ្វើការបកស្រាយយ៉ាងតឹងរ៉ឹង[18]។"

### គ. សេចក្តីសង្កេតលើសំណួរទី៣

២០. លោក ខៀវ សំផន សូមលើកឡើងជាថ្មីនូវអំណះអំណាង នៅក្នុងកថាខណ្ឌទី៣១ ដល់ទី៣៤ នៃការបណ្តឹងរបស់លោក អៀង សារី ប្រឆាំងនឹងការអនុវត្តរបស់ អ.វ.ត.ក លើបទឧក្រិដ្ឋ ដែលមានចែងនៅក្នុងមាត្រា៣ ថ្មី នៃច្បាប់បង្កើត អ.វ.ត.ក (បទល្មើសនៅក្នុងច្បាប់ជាតិ)[19] ព្រមទាំងអំណះអំណាងដែលលើកឡើងដោយ កាំង ហ្កេកអ៊ាវ ហៅឌុច ពីកថាខណ្ឌទី១៣ ដល់ទី២៥ នៃដីកាសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ទាក់ទងនឹងអញ្ញត្រកម្មបឋមដែលលើកឡើងដោយក្រុមការពារក្តី[20]។

### ឃ. សេចក្តីសង្កេតលើសំណួរទី៤

២១. លោក ខៀវ សំផន ទទួលរងនូវការទទួលខុសត្រូវជាថ្មីទៀតហើយចំពោះអំណះអំណាង ដែលលើកឡើងដោយ កាំង ហ្កេកអ៊ាវ ហៅឌុច នៅកថាខណ្ឌទី២៦ ដល់ទី២៩ នៅក្នុង សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់ខ្លួន ទាក់ទងនឹងអញ្ញត្រកម្មបឋមដែលលើកឡើងនោះ[21]។

---

[18] សេចក្តីសម្រេចស្តីពីអញ្ញត្រកម្មទាក់ទងនឹងថិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសក្នុងច្បាប់ជាតិដែលលើកឡើង ដោយមេធាវីការពារក្តី ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារតុលាការ E187 កថាខណ្ឌទី៤៤ ។

[19] ញត្តិរបស់លោក អៀង សារី ប្រឆាំងនឹងការអនុវត្តឧក្រិដ្ឋកម្មនានាដែល មានចែងនៅក្នុងមាត្រា៣ ថ្មី នៃច្បាប់បង្កើត អ.វ.ត.ក (បទល្មើសនៅក្នុងច្បាប់ជាតិ) ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០

[20] សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ស្តីពីអញ្ញត្រកម្មលើកឡើងដោយក្រុមការពារក្តី ថ្ងៃទី១៨ ខែឧសភា ឆ្នាំ ២០០៩ ឯកសារតុលាការ E9/9

[21] សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ស្តីពីអញ្ញត្រកម្មលើកឡើងដោយក្រុមការពារក្តី ថ្ងៃទី១៨ ខែឧសភា ឆ្នាំ

២២. ម្យ៉ាងវិញទៀត ចៅក្រមអន្តរជាតិបានគូសបញ្ជាក់ថា សញ្ញាណនៃការគ្រោងទុកជាមុន នៃសុវត្ថិភាពគតិយុត្តិ និងការកាត់សេចក្តីប្រកបដោយយុត្តិធម៌ បានជម្រុញឱ្យ "អ្នកច្បាប់ជាតិមួយចំនួន ដូចជាតុលាការសិទ្ធិមនុស្សអឺរ៉ុប (CEDH) ត្រូវចាត់ទុកថាការពន្យារពេលអាជ្ញាយុកាលនៃទោសអាចធ្វើទៅបាន លុះត្រាតែថិរវេលានៃអាជ្ញាយុកាលនោះ មិនទាន់ផុតរលត់ប៉ុណ្ណោះ។ នៅក្នុងសេចក្តីសម្រេចក្នុងរឿងក្តី Kononov តុលាការសិទ្ធិមនុស្សអឺរ៉ុប បានបកស្រាយមាត្រា៧ នៃអនុសញ្ញាសិទ្ធិមនុស្សអឺរ៉ុប ក្នុងគោលបំណងដើម្បីទប់ស្កាត់មិនឱ្យធ្វើបណ្តឹងអាជ្ញាជាថ្មី ចំពោះបទឧក្រិដ្ឋក្នុងច្បាប់ជាតិ ដែលបានផុតរលត់ថិរវេលានៃអាជ្ញាយុកាល[22]។

### ង. សេចក្តីសង្កេតលើសំណួរទី៥

២៣. អង្គជំនុំជម្រះបានស្នើចោទសួរទៅភាគីថា តើផលវិបាកគតិយុត្តិនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០១ មកលើ អ.វ.ត.ក មានដូចម្តេចខ្លះ។ លោក ខៀវ សំផន កត់សម្គាល់ថា ដីកាសម្រេចពិតជាគ្មានអានុភាពអ្វីសោះឡើយទៅលើ អ.វ.ត.ក។ ដីកាសម្រេចកម្រិតត្រឹមតែការត្រួតពិនិត្យទៅលើលក្ខណៈធម្មនុញ្ញភាពរបស់ច្បាប់ស្តីពី អ.វ.ត.ក ទៅនឹងរដ្ឋធម្មនុញ្ញតែប៉ុណ្ណោះ។ ដីកាសម្រេចចាត់ទុកថា គោលការណ៍អប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ ពុំមានចរិតលក្ខណៈធម្មនុញ្ញឡើយ ហើយមិនធ្វើការត្រួតពិនិត្យទៅលើចំណុចនេះឡើយ។ ទាំងអស់នេះមិនអាចអនុញ្ញាតឱ្យអង្គជំនុំជម្រះ បំពានទៅលើគោលការណ៍អប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ នៅក្នុងគោលការណ៍អន្តរជាតិដែលត្រូវតែគោរពតាមនោះឡើយ (មាត្រា ១១ នៃសេចក្តីថ្លែងការណ៍ជាសាកលស្តីពីសិទ្ធិមនុស្ស មាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ)។ ជាទូទៅ ការត្រួតពិនិត្យលើធម្មនុញ្ញភាពកម្រិតត្រឹមតែការត្រួតពិនិត្យភាពស្របច្បាប់ ជាមួយនឹងរដ្ឋធម្មនុញ្ញប៉ុណ្ណោះ គឺមិនរហូតដល់ការត្រួតពិនិត្យទៅលើច្បាប់ ជាមួយនឹងអនុសញ្ញាឡើយ។ ការត្រួតពិនិត្យទៅលើភាពស្របនឹងអនុសញ្ញាអាចត្រូវធ្វើឡើងដោយចៅក្រមនៃ អ.វ.ត.ក។ ព្រោះថា មាត្រា

---

២០០៩ ឯកសារតុលាការ E9/9

[22] សេចក្តីសម្រេចស្តីពីអញ្ញត្រកម្មទាក់ទងនឹងថិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសក្នុងច្បាប់ជាតិដែលលើកឡើងដោយមេធាវីការពារក្តី ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារតុលាការ E187 កថាខណ្ឌទី៥០ ។

៣៣ថ្មី ចែងថា៖ "អង្គជំនុំជម្រះវិសាមញ្ញសាលាដំបូងត្រូវប្រព្រឹត្តទៅឱ្យបានត្រឹមត្រូវ និងឆាប់រហ័សទៅតាមនីតិវិធីជាធរមាន ដោយមានការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនត្រូវចោទ និងមានការការពារឱ្យបានត្រឹមត្រូវចំពោះជនរងគ្រោះ និងសាក្សី។ ប្រសិនបើនីតិវិធី ដែលមានស្រាប់ពុំបានចែងពីករណីពិសេសមួយ ឬបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬអនុវត្តនីតិវិធីនោះ ឬបើមានបញ្ហាទាក់ទងនឹងភាពសមស្របនៃនីតិវិធីទាំងនេះជាមួយបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ។[23] "

## IV. **សេចក្តីសន្និដ្ឋាន**

២៤. អញ្ញត្រកម្មបឋមមានបំណងកំណត់យុត្តាធិការនៃអង្គជំនុំជម្រះ មុននឹងចាប់ផ្តើមសវនាការ។ លោក ខៀវ សំផន មានសិទ្ធិទទួលបានព័ត៌មានអំពីការដាក់បន្ទុកប្រឆាំងនឹងរូបលោក[24] ហើយមានសិទ្ធិមានពេលវេលា និងការបង្កភាពងាយស្រួលចាំបាច់ដល់ការរៀបចំការពាររូបលោក[25]។ នៅក្នុងករណីដែលលោកមានថិរវេលាខ្លីពេកសម្រាប់ដាក់សារណារបស់លោក (៣០ថ្ងៃបន្ទាប់ពីពេលដែលដីកាដំណោះស្រាយចូលជាស្ថាពរ) ពុំមានអ្វីដែលបញ្ជាក់ថា អង្គជំនុំជម្រះអាចលើកចម្លើយរបស់ខ្លួនទៅពេលក្រោយ គឺនៅពេលសម្រេចទៅលើសាលក្រមនោះឡើយ។ នៅក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះសាលាដំបូង បានប្រកាសលើអញ្ញត្រកម្មបឋមស្តីពីការរលត់បណ្តឹងអាជ្ញា ដែលលើកឡើងដោយ កាំង ហ្គេកអ៊ាវ ហៅឌុច នៅថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ២០១០ គឺថានៅទន្ទឹមនឹងពេលដែលការវិនិច្ឆ័យទៅលើអង្គសេចក្តី (ស្របតាមវិធាន ៨៩ (៣) នៃវិធានផ្ទៃក្នុង)[26]។ លោក ខៀវ សំផន លើកឡើងថា ការលើកពេលបែបនេះប៉ះពាល់ដល់ការពិភាក្សាលើអង្គសេចក្តី។ ប្រសិនបើអង្គជំនុំជម្រះបានប្រកាស "ពី

[23] មាត្រា៣៣ ថ្មី ច្បាប់ឆ្នាំ២០០៤ ស្តីពីការបង្កើត អ.វ.ត.ក ។

[24] មាត្រា ៩(២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

[25] មាត្រា ១៤(៣) (ខ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ មាត្រា៣៣ ថ្មី ច្បាប់ឆ្នាំ ២០០៤ ស្តីពីការបង្កើត អ.វ.ត.ក ។

[26] សេចក្តីសម្រេចស្តីពីអញ្ញត្រកម្មទាក់ទងនឹងថិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសក្នុងច្បាប់ជាតិដែលលើកឡើងដោយមេធាវីការពារក្តី ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារតុលាការ E187 កថាខណ្ឌទី៥៦ ។

ការរាំងស្ទះដល់ការបន្តធ្វើបណ្តឹងអាជ្ញាប្រឆាំងនឹងជនជាប់ចោទ ចំពោះបទល្មើសនៅក្នុងច្បាប់ជាតិ” មុនបើកសវនាការមែននោះ ម្ល៉េះសមអង្គជំនុំជម្រះអាចផ្តោតការយកចិត្តទុកដាក់ ទៅលើបន្ទុកផ្សេងទៀតលើជនជាប់ចោទជាមិនខាន។ លោក ខៀវ សំផន ស្នើសុំអង្គជំនុំជម្រះមេត្តាឆ្លើយទៅនឹងអញ្ញត្រកម្មបឋមដែលលើកឡើងមុនសវនាការបឋម ព្រោះលោកចង់បាននូវភាពច្បាស់លាស់ និងគុណភាពនៃការពិភាក្សា។

## ហេតុដូច្នេះ

២៨. សូមអង្គជំនុំជម្រះសាលាដំបូង មេត្តា៖

- ប្រកាសថា បណ្តឹងនេះអាចទទួលយកបាន និងមានមូលដ្ឋានត្រឹមត្រូវ
- ប្រកាសថា បណ្តឹងអាជ្ញានេះរលត់ចំពោះមុខបញ្ញត្តិនៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦
- ប្រកាសសាលក្រម មុនបើកសវនាការពិភាក្សាលើអង្គសេចក្តី។

## រក្សាសិទ្ធិកែប្រែគ្រប់យ៉ាង

## និងដើម្បីយុត្តិធម៌

| | | | |
|---|---|---|---|
| | មេធាវី ស សូវាន | ភ្នំពេញ | |
| | មេធាវី Jacques VERGÈS | ប៉ារីស | |
| | មេធាវី Philippe GRECIANO | ប៉ារីស | |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |